នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Nov-2012, 12:39
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំទំព័រដែលបាត់នៅក្នុងឯកសារលេខ E3/1173**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម យ៉ា ឧត្តរា
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

លោក Michael
G.KARNAVAS
លោក គង់ សំអុន
Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

# សំណើ

១- នៅពេលដំណើរការបង្ហាញឯកសារជូនអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ តំណាងសហព្រះរាជអាជ្ញា លោក Lysak បានបង្ហាញឯកសារលេខ E3/1173[1]។ គាត់បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ឯកសារដើមមានចំនួន៣ទំព័រ ប៉ុន្តែគាត់មានតែទំព័រទី១ និងទី២ ប៉ុណ្ណោះ ដោយបាត់ទំព័រទី២។ គាត់បានលើកសំណូមពរថា ការសាកសួរព័ត៌មានបន្ថែមទៀតទាក់ទងនឹងការបាត់នេះ អាចធ្វើឡើងដោយសហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ជាក់ពីគោលជំហរនេះ។

២- នៅក្នុងថ្ងៃដដែលនោះ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង បានទាក់ទងតាមអ៊ីម៉ែលមកសហព្រះរាជអាជ្ញា ដោយបញ្ជាក់ថា អង្គភាពឯកសារ និងបណ្ណសារ មិនធ្លាប់បានទទួលឯកសារទំព័រទីពីរទាល់តែសោះ។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់បានបញ្ជូនសំណើរបស់លោកប្រធានអង្គជំនុំជម្រះសាលាដំបូង ថាត្រូវទំនាក់ទំនងទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដើម្បីឱ្យបញ្ជាក់ឱ្យច្បាស់ថាទំព័រដែលបាត់នោះនៅកន្លែងណា។ ភ្លាមៗនោះ សហព្រះរាជអាជ្ញាបានទាក់ទងទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលឥឡូវនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ថា ខ្លួនបានទទួលឯកសារនេះមួយច្បាប់ពីលោកសាស្ត្រាចារ្យ Ben Kiernan ដែលក្នុងនោះមានតែទំព័ទី១ និងទំព័រទី៣ តែប៉ុណ្ណោះ។

៣- ដោយសារឯកសារលេខ E3/1173 មានសារៈសំខាន់ សហព្រះរាជអាជ្ញាស្នើឱ្យទាក់ទងជាមួយនឹងលោកសាស្ត្រាចារ្យ Kiernan ហើយសុំឱ្យគាត់ផ្តល់ទំព័រទី២ ប្រសិនបើគាត់មាន។ សហព្រះរាជអាជ្ញាមានបំណងទាក់ទងជាមួយនឹងលោកសាស្ត្រាចារ្យ Kiernan ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |

[1] ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី១១៨ (ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២) ទំព័រទី៥៥ បន្ទាត់ទី១១។